# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ: [illegible]

ថ្ងៃ ព្រហស្បតិ៍ ៤រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

**- ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**- ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**- ឯកឧត្តមអគ្គលេខាធិការគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា**

**កម្មវត្ថុ៖** ករណីសូមគោរពជម្រាបជូន សម្តេចតេជោនាយករដ្ឋមន្ត្រី ស្តីពីការលុបចោលការប្រកួតអាស៊ានប៉ារ៉ាហ្គេមលើកទី១០ ដែលគ្រោងប្រព្រឹត្តទៅនៅប្រទេសហ្វីលីពីន និងគោរពស្នើសុំការអនុញ្ញាតដើម្បីលើកទឹកចិត្តជូនគ្រូបង្វឹកនិងអត្តពលិកជនពិការ សរុបចំនួន ១០១នាក់ ដែលម្នាក់ៗចំនួន ២ ០០០ ០០០រៀល ពីខ្ទង់គ្រោងចំណាយសម្រាប់ការប្រកួតអាស៊ានប៉ារ៉ាហ្គេមលើកទី១០។

**យោង** ៖ -លិខិតលេខ០២៩/គជបក/២០២០ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា។

-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលយល់ព្រមឧបត្ថម្ភជូនគ្រូបង្វឹកនិងអត្តពលិកជនពិការ សរុបចំនួន ១០១នាក់ ដើម្បីជាការលើកទឹកចិត្តសម្រាប់ចំណាយកន្លងមក ដោយប្រើប្រាស់ថវិកាមានស្រាប់តាមរយៈក្រសួងអប់រំ យុវជន និងកីឡា ដែលគ្រោងសម្រាប់ចូលរួមប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី១០ នៅប្រទេសហ្វីលីពីន រួចបុរេប្រទាននៅសល់បង្វិលចូលខ្ទង់ថវិកាវិញ។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**អ៊ុន វីរជាតិ**

**ចម្លងជូន៖**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ឯកសារ កាលប្បវត្តិ

(1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

សូមគោរពជូន
ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី

13/07

**កម្មវត្ថុ ៖ សំណើសុំអនុញ្ញាតបញ្ជូនឯកសារទៅអង្គភាពពាក់ព័ន្ធ។**

**ខ្លឹមសារ៖**

១. ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ស្នើសុំការផ្តល់ Comments និង Inputs លើសេចក្តីព្រាងឯកសារគោលចំនួន ០២ នៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសមេគង្គ-សាធារណរដ្ឋកូរ៉េលើកទី១០ ដែលគ្រោងធ្វើនៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ ខាងមុខ។ សូមផ្ញើត្រឡប់មកមុនថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ២០២០ ។ **សូមគោរពជូនឯកឧត្តម ឌី ខាំបូលី និងនាយកដ្ឋានផែនការ។**

២. ទីភ្នាក់ងារសហព័ន្ធសម្រាប់កិច្ចការយុវជន និងរដ្ឋាភិបាលនៃតំបន់ Orenburg នៃសហព័ន្ធរុស្ស៊ី ជូនដំណឹងស្តីពីការរៀបចំវេទិកាលើកទី 5 International Youth Forum " Eurasia Global" ដែលប្រព្រឹត្តទៅនៅថ្ងៃទី ០២-០៨ ខែកញ្ញា ឆ្នាំ២០២០ នៅទីក្រុង Orenburg សហព័ន្ធរុស្ស៊ី។ អ្នកចូលរួមត្រូវមានអាយុចន្លោះពី ១៨ ដល់ ៣៥ឆ្នាំ និងត្រូវរ៉ាប់រងការចំណាយដោយខ្លួនឯង ហើយការចុះឈ្មោះត្រូវធ្វើឡើងតាមគេហទំព័រ forumeurasia.ru ឲ្យបានមុនថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០២០ ។ **សូមជូន អគ្គនាយកដ្ឋានយុវជន ។**

៣. ទីស្តីការគណៈរដ្ឋមន្ត្រី ជូនដំណឹងអំពី រាជរដ្ឋាភិបាលយល់ព្រមឧបត្ថម្ភជូនគ្រូបង្វឹក និងអត្តពលិកជនពិការសរុបចំនួន ១០១ នាក់ ដើម្បីជាការលើកទឹកចិត្តសម្រាប់ចំណាយកន្លងមក ដោយប្រើបុរេប្រទានមានស្រាប់ តាមរយៈក្រសួងអប់រំ យុវជន និងកីឡាដែលគ្រោងសម្រាប់ចូលរួមប្រកួតកីឡាអាស៊ានប៉ារ៉ាហ្គេមលើកទី ១០ នៅប្រទេសហ្វីលីពីន រួចបុរេប្រទាននៅសល់បង្វិលចូលខ្ទង់ថវិការដ្ឋវិញ។ **សូមជូន នា. ហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានកីឡា ។**

៤. ទីស្តីការគណៈរដ្ឋមន្ត្រី ជូនដំណឹងអំពី រាជរដ្ឋាភិបាលសម្រេចមិនអនុញ្ញាតឲ្យបើក "សាកលវិទ្យាល័យតេជោសាឡាមអន្តរជាតិកម្ពុជា" របស់អង្គការក្រុមប្រឹក្សាអ៊ីស្លាមអភិវឌ្ឍន៍កម្ពុជាឡើយ ។ **សូមជូន នា. ឧត្តមសិក្សា ។**

៥. ក្រសួងមហាផ្ទៃ ជម្រាបជូនអំពី ការគាំទ្រលើសកម្មភាព និងសមិទ្ធផលនានារបស់អង្គការ School Aid Japan ក្នុងរយៈពេល ២០ឆ្នាំ នៅប្រទេសកម្ពុជា ដោយបានចំណាយអស់ថវិកា ១០.៩១៣.៣៣៥.០៥ ដុល្លារ ក្នុងការសាងសង់អគារសិក្សាជាច្រើន ព្រមទាំងសកម្មភាពមនុស្សធម៌នៅតាមបណ្តាខេត្តមួយចំនួន ជាពិសេសជួយឧបត្ថម្ភកុមារគ្រួសារក្រីក្រនៅតាមសាលាបឋមសិក្សា និងការលើកកម្ពស់សមត្ថភាពសិក្សារបស់សិស្សវិទ្យាល័យនៅតាមតំបន់ជនបទ ។ **សូមជូន នាយកដ្ឋាន ទវអ. ។**

៦. អាជ្ញាធរសវនកម្មជាតិ ស្នើសុំពិនិត្យ និងធ្វើការឆ្លើយបំភ្លឺជាលាយលក្ខណ៍អក្សរលើរបាយការណ៍ ក្នុងអំឡុងពេល ២៨ ថ្ងៃ ។ **សូមជូន នាយកដ្ឋានហិរញ្ញវត្ថុ ។**

NATIONAL PARALYMPIC COMMITTEE OF CAMBODIA

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ចូល មកដល់ការិយាល័យ ... លេខ 3292
លើកទី១ថ្ងៃ 13 ខែ 07 ឆ្នាំ 20 ម៉ោង
លេខៈ ... /គជបក ២០២០
ថ្ងៃទី 08 ខែ 07 ឆ្នាំ 2020

ថ្ងៃពុធ ៣រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
រាជធានីភ្នំពេញ, ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០

**គោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ**៖ គោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** ស្តីពីការលុបការប្រកួតអាស៊ានប៉ារ៉ាហ្គេមលើកទី១០ និងការឧបត្ថម្ភជូន គ្រូបង្វឹកនិងអត្តពលិកចំនួន១០១នាក់ដែលម្នាក់ៗទទួលបាន ២ ០០០ ០០០រៀល ពីខ្ទង់គ្រោងចំណាយសម្រាប់ការប្រកួតអាស៊ានប៉ារ៉ាហ្គេមលើកទី១០។

**យោង**៖ -លិខិត លេខៈ១៣៤ សជណ ចុះថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០ របស់ ទីស្តីការ គណៈរដ្ឋមន្ត្រី

-លិខិត លេខៈ៦៥៨ សជណ.អវ ចុះថ្ងៃអង្គារ ២រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០

-លទ្ធផលកិច្ចប្រជុំក្រុមប្រឹក្សាភិបាល សហព័ន្ធកីឡាជនពិការអាស៊ាន តាមវីដេអូ (Sico Webex)

តបតាមកម្មវត្ថុនិងយោងជម្រាបជូនខាងលើសូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** មេត្តាជ្រាបថា ក្រុមប្រឹក្សាភិបាលសហព័ន្ធកីឡាជនពិការអាស៊ានបានរៀបចំកិច្ចប្រជុំតាមវីដេអូ(Sico Webex)ពីថ្ងៃទី១៩ខែមិថុនាឆ្នាំ២០២០ សម្រេចលុបការប្រកួតអាស៊ានប៉ារ៉ាហ្គេមលើកទី១០ ជាស្ថាពរ ដោយម្ចាស់ផ្ទះហ្វីលីពីនសុំមិនបន្តរៀបចំ អាស៊ានប៉ារ៉ាហ្គេមលើកទី១០មូលហេតុជម្ងឺឆ្លងកូវីដ-១៩និងសន្ទស្សន៍ថវិកាសម្រាប់ដោះស្រាយក្នុងប្រទេសហ្វីលីពីន។ ក្រុមប្រឹក្សាភិបាលសហព័ន្ធកីឡាជនពិការអាស៊ានបាន សម្រេចបន្តរៀបចំការប្រកួត អាស៊ានប៉ារ៉ាហ្គេមលើកទី១១ ប្រទេសវៀតណាមដល់វេនធ្វើជាម្ចាស់ផ្ទះឆ្នាំ២០២១។

យោងតាមស្ថានភាពដូចគោរពជម្រាបប្រសាសន៍ខាងលើ គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា បានធ្វើលិខិតគោរពជម្រាបជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** រួចហើយ និងបានគោរពស្នើសុំថវិកា ដើម្បីលើកទឹកចិត្តដល់គ្រូបង្វឹកនិងអត្តពលិកជនពិការរបស់កម្ពុជាចំនួន១០១នាក់ម្នាក់ៗទទួលបានថវិកា ២ ០០០ ០០០រៀល ពីបុរេប្រទានសម្រាប់គ្រោងចំណាយអាស៊ានប៉ារ៉ាហ្គេមលើកទី១០ តាមរយៈក្រសួងអប់រំ យុវជន និងកីឡា។ ករណីដូចគោរពជម្រាបប្រសាសន៍ខាងលើនេះ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានយល់ព្រមនិងមាន សជណ.អវ លេខ ៦៥៨។

អាស្រ័យដូចបានគោរពជម្រាបខាងលើ **សូមឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រី** មេត្តាជ្រាប និងសម្រួលបានប្រើប្រាស់បុរេប្រទានតាមរយៈ ក្រសួងអប់រំ យុវជន និងកីឡា ដោយក្តីអនុគ្រោះបំផុត។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យ** ទទួលបាននូវពុទ្ធពរគឺ អាយុ វណ្ណៈ សុខៈនិងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ជ.គណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកកម្ពុជា**
**អគ្គលេខាធិការ**

NATIONAL PARALYMPIC COMMITTEE OF CAMBODIA

**ឃី ខាសនា**

**ចម្លងជូន**៖
-សេចក្តីរាយការណ៍តាមប្រព័ន្ធ Facebook មួយច្បាប់

## Board of Governors members



Mr.Michael Barredo
Board of Governors Chairman
BOG member



Maj Gen Ocnth Phavilai
Board of Governors Secretary/
BoG member

Like Comment Share




APSF

# THE APSF 22nd Board of Governors Emergency Meeting 19th June 2020

**Asean Para Sports Federation** is with **Wandee Tosuwan** and **2 others**.
Sunday at 1:48 PM ·

MEDIA RELEASE

Sunday, 21 June 2020

APSF BOARD of GOVERNORS (BoG) OFFICIALLY ENDORSES CANCELLATION OF 2020 GAMES – MOVES FORWARD FOR 2021 VIETNAM GAMES

1. The ASEAN Para Games Federation (APSF) has officially endorsed the cancellation of the 10th ASEAN Para Games Philippines 2020 and looks forward to the successful staging of the 11th ASEAN Para Games scheduled in Vietnam next year.

2. APSF's Board of Governors (BoG) convened an emergency video conference meeting on Friday (19 June 2020), chaired by Mr Michael Barredo, president of the NPC Philippines and attended by presidents from

manpower and other technical requirements.

5. The focus for APSF now is to ensure early preparation and coordination to ensure the successful staging of the 11th ASEAN Para Games, scheduled to be hosted in Hanoi, Vietnam in December 2021.

6. Vietnam will be hosting the Games for the second time after a lapse of 18 years. The country last hosted the second edition of the Games in 2003 where only 5 sports were contested.

7. Board members unanimously extended their appreciation, thanking the government of the Philippines and PHILAPGOC for the commitment and efforts undertaken at all levels towards the organising of the 10th ASEAN Para Games.

8. The biennial Games was last hosted by Malaysia in Kuala Lumpur in 2017.

with new challenges in Vietnam 2021.

Thank you.

MAJOR GENERAL OSOTH BHAVILAI

President

ASEAN PARA SPORTS FEDERATION (APSF)






II

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី**

13/07

**សូមគោរពជូន**
**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី**

**កម្មវត្ថុ ៖ សំណើសុំអនុញ្ញាតបញ្ជូនឯកសារទៅអង្គភាពពាក់ព័ន្ធ។**

**ខ្លឹមសារ៖**

**១.** ទីស្តីការគណៈរដ្ឋមន្ត្រី ស្នើសុំចាត់តំណាងជារដ្ឋលេខាធិការ ដើម្បីចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យ និងពិភាក្សាបន្តលើសេចក្តីព្រាងផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៩-២០២៣ នាថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៨:៣០ នាទី និង ១៥:០០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ **សូមគោរពជូន លោកជំទាវ សឿ សុជាតា ។**

**២.** គណៈកម្មាធិការជាតិ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ស្នើសុំអញ្ជើញ លោកជំទាវ ទន់ សាអឹម អនុរដ្ឋលេខាធិការ ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ៩ព្រឹក នៅទីស្តីការក្រសួងកិច្ចការនារី ។ **សូមគោរពជូន លោកជំទាវ ទន់ សាអឹម ។**

**៣.** ក្រសួងផែនការ ស្នើសុំមន្ត្រីបច្ចេកទេសចំនួន ០២រូប ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួងដើម្បីពិភាក្សាកែសម្រួលបញ្ជីសូចនាករគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក.) ២០១៦-២០៣០ នាថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៨:៣០នាទីព្រឹក នៅសណ្ឋាគារកាំបូឌីយ៉ាណា។ **សូមជូន អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ ។**

**៤.** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្នើសុំក្រសួងអប់រំ យុវជន និងកីឡា ផ្តល់ធាតុចូលលើសេចក្តីព្រាងផែនការសកម្មភាពជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៩-២០២៣ ដែលសេចក្តីព្រាងនេះនឹងត្រូវលើកក្នុងកិច្ចប្រជុំអន្តរក្រសួងលើកទី២ និងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាពេលខាងមុខ ។សូមផ្ញើមកឲ្យបានមុនថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២០។ **សូមជូន នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ។**

**៥.** គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្នើសុំជូនយោបល់បន្ថែមលើសេចក្តីព្រាងឯកសារ ស្តីពីជម្រើសនានាសម្រាប់លើកកម្ពស់កិច្ចសហប្រតិបត្តិការ អាស៊ាន-អូស្ត្រាលី ឆ្លើយតបនិងការជាសះស្បើយឡើងវិញពីជំងឺកូវីដ ១៩ ។ **សូមជូន នាយកដ្ឋាន អាស៊ាន ។**

**៦.** ទីស្តីការគណៈរដ្ឋមន្ត្រី ស្នើសុំចាត់តំណាងជារដ្ឋលេខាធិការ ០១រូប ដើម្បីចូលរួមក្នុងអង្គប្រជុំអន្តរក្រសួងចង្អៀត ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារ នាថ្ងៃទី ១៦-១៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ០៨:៣០ នាទី នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ **សូមគោរពជូន លោកជំទាវ យុន រចនា និងជូន នាយកដ្ឋានសុខភាពសិក្សា ។**